

សួស្តី! ខ្ញុំឈ្មោះរតនា។
ខ្ញុំគឺជាចៅស្រី កូនស្រី បងប្អូនស្រី ក្មួយស្រីនិងបងប្អូនជីដូនមួយម្នាក់ផងដែរ។

មនុស្សម្នាក់សោះ បែរជាមានតួនាទីយ៉ាងច្រើន។
តើមកពីហេតុអ្វីទៅ?



នេះគឺជាមករា។
គាត់គឺជាចៅប្រុស កូនប្រុស បងប្អូនប្រុស ក្មួយប្រុសនិងបងប្អូនជីដូនមួយម្នាក់ផងដែរ។

តើហេតុអ្វីទៅ?
ចាំខ្ញុំរៀបរាប់ប្រាប់អ្នកទាំងអស់គ្នា!



នេះគឺជាលោកតាលោកយាយរបស់ខ្ញុំ។ ខាងឆ្វេងគឺជាឪពុកម្ដាយរបស់ម្ដាយខ្ញុំ។ រីឯខាងស្ដាំគឺជាឪពុកម្ដាយរបស់ឪពុកខ្ញុំ។ មករាគឺជាចៅប្រុសរបស់ពួកគាត់។ ឯខ្ញុំវិញក៏ជាចៅស្រីរបស់ពួកគាត់ដែរ។



នេះគឺជាម្ដាយរបស់ខ្ញុំ។
គាត់ក៏ជាកូនស្រីម្នាក់ដូចខ្ញុំអ៊ីចឹងដែរ ព្រោះគាត់ជាកូនស្រីរបស់លោកតាលោកយាយខ្ញុំ។



នេះគឺជាឪពុករបស់ខ្ញុំ។
គាត់ក៏ជាកូនប្រុសម្នាក់ដូចមករាអ៊ីចឹងដែរ ព្រោះគាត់ជាកូនប្រុសរបស់លោកតាលោកយាយខ្ញុំ។



នេះគឺជាដារិន។

គាត់ជាកូនស្រីរបស់លោកតាលោកយាយខ្ញុំ ហើយក៏ជាមីងរបស់ខ្ញុំផងដែរ។

គាត់និងឪពុកខ្ញុំជាបងប្អូនបង្កើតនឹងគ្នា ដូចខ្ញុំនិងមករាអ៊ីចឹង។

មករានិងខ្ញុំជាក្មួយប្រុសក្មួយស្រីរបស់គាត់។ គាត់បានរៀបការជាមួយវិច្ឆិកា

ដូច្នេះវិច្ឆិកាក្លាយជាពូសាច់ថ្លៃរបស់ពួកខ្ញុំ។



នេះគឺជាឆន្ទៈ។

គាត់ជាកូនប្រុសរបស់លោកតាលោកយាយខ្ញុំ ហើយក៏ជាអ៊ំប្រុសរបស់ខ្ញុំដែរ។

គាត់និងម្ដាយខ្ញុំជាបងប្អូនបង្កើតនឹងគ្នា ដូចខ្ញុំនិងមករាអ៊ីចឹង។

មករានិងខ្ញុំជាក្មួយប្រុសក្មួយស្រីរបស់គាត់។ គាត់បានរៀបការជាមួយសុខណា

ដូច្នេះសុខណាក្លាយជាអ៊ំស្រីសាច់ថ្លៃរបស់ពួកខ្ញុំ។



មករានិងខ្ញុំគឺជាចៅប្រុសចៅស្រីរបស់លោកតាលោកយាយ។
ពួកខ្ញុំក៏ជាក្មួយប្រុសក្មួយស្រីរបស់អ៊ំប្រុសអ៊ំស្រីនិងពូមីង
ព្រមទាំងជាកូនប្រុសកូនស្រីរបស់ឪពុកម្ដាយពួកខ្ញុំផងដែរ។



នេះគឺជាស៊ីថា។

គាត់ជាក្មួយប្រុសឪពុកម្ដាយខ្ញុំ ត្រូវជាបងប្អូនជីដូនមួយខាងឪពុករបស់ខ្ញុំ។

គាត់ជាកូនប្រុសរបស់មីង ហើយក៏ត្រូវជាចៅប្រុសរបស់លោកតាលោកយាយខ្ញុំផងដែរ។




នេះគ្រាន់តែរៀបរាប់បីជំនាន់នៃគ្រួសារខ្ញុំតែប៉ុណ្ណោះ។

លោកតាលោកយាយជាជំនាន់ទីមួយនៅក្នុងតារាងពង្សាវតារនេះ។

ឪពុកម្ដាយ អ៊ំប្រុសអ៊ំស្រីនិងពូមីងរបស់ខ្ញុំជាជំនាន់ទីពីរ។

រីឯខ្ញុំ មករានិងបងប្អូនជីដូនមួយរបស់ពួកខ្ញុំជាជំនាន់ទីបី។



ពេលដែលខ្ញុំធំឡើង ហើយមានកូន ពួកគេនឹងក្លាយជាជំនាន់ថ្មី។ ខ្ញុំនឹងក្លាយជាម្ដាយម្នាក់។ មករានឹងក្លាយជាពូ ហើយឪពុកម្ដាយខ្ញុំនឹងក្លាយជាលោកតាលោកយាយវិញម្ដង។



អ្នកខ្លះអាចតាមដានពង្សាវតាររបស់គាត់បានជាច្រើនជំនាន់។
អ្នកខ្លះក៏រកឃើញថា គាត់ជាប់សាច់ឈាមជាមួយនឹងបុគ្គលល្បីល្បាញ។
អ្នកខ្លះទៀតក៏រកឃើញថា គ្រួសារគាត់មានពូជអម្បូរមកពីប្រទេសផ្សេងៗផងដែរ៕

ចុះគ្រួសាររបស់អ្នកវិញ?




# មែកធាងគ្រួសារ

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary